00154259

C5/45

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០១)**

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជីសវនាការ** ជួន សុរាសី
Anne-Marie Burns

**កាលបរិច្ឆេទ:** ០៣ ធ្នូ ២០០៧

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 05 ខែ(Month/Mois) DEC
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier NUP SOTHUN VICHET

---

## សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

---

**អនុលោមតាម** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង តាមវិធាន ៦៣(៤) នៃវិធានផ្ទៃក្នុង

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**
**ជា លាង**
**Robert PETIT**

**<u>ជនត្រូវចោទ</u>**
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**<u>មេធាវីការពារក្តី</u>**
ការ សាវុត
**François Roux**

ORIGINAL DOCUMENT
RECEIVED ON 04/12/2007
AT 15:40' BY
NUP SOTHUN VICHET
ACTING CASE FILE
OFFICER

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C. អង្គបុរេជំនុំជម្រះ

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក"**

**ដោយយល់ឃើញថា** ក្នុងការសរសេរសាលដីកានេះ អង្គបុរេជំនុំជម្រះយល់ពីភាពចាំបាច់របស់សាធារណៈជនដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាលលើវិស័យច្បាប់ ដើម្បីយល់និងឱ្យតម្លៃលើខ្លឹមសារនិងអត្ថន័យនៃសាលដីការបស់ខ្លួន ។ ចៅក្រមអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថាសាធារណៈជនមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើកិច្ចដំណើរការនីតិវិធីរបស់អង្គបុរេជំនុំជម្រះ។ ដូច្នេះយើងសរសេរសាលដីកានេះក្នុងទម្រង់មួយដើម្បីជាការឆ្លើយតបទៅនឹងភាពចាំបាច់នេះ។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច** ដូចខាងក្រោម:

## ជំពូក ១ - សេចក្តីផ្តើម

១. អង្គបុរេជំនុំជម្រះ យោងទៅលើរបាយការណ៍ដែលត្រូវបានពិនិត្យនិងអនុម័តកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ លើនីតិវិធី អង្គច្បាប់ និងអង្គហេតុក្នុងសំណុំរឿងនេះ ដែលជាផ្នែកមួយនៃសាលដីកានេះ។

២. កាលពីថ្ងៃទី១៥ ទី២០ និងទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានបើកសវនាការជាសាធារណៈខ្លះ និងជាសម្ងាត់ខ្លះ។

៣. មុនថ្ងៃសវនាការ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿងដែលត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុត។

## ជំពូក ២ - ភាពអាចទទួលយកបានលើបណ្តឹងឧទ្ធរណ៍

៤. កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ សហមេធាវីរបស់ជនត្រូវចោទបានប្រកាសបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ តាមដីកាបង្គាប់របស់ក្រឡាបញ្ជីនាយកចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវីដាក់សារណារបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃ[illegible]ជូនដំណឹងពីដីកានេះ។ សហមេធាវីបានដាក់សារណាប្តឹងឧទ្ធរណ៍នេះនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧[illegible]

ពោលគឺសារណានេះបានដាក់ជូនអង្គបុរេជំនុំជម្រះក្នុងថេរវេលាកំណត់ ដូច្នេះបណ្តឹងឧទ្ធរណ៍នេះគឺអាចទទួលយកបាន។

៥. សហព្រះរាជអាជ្ញាបានសុំឱ្យអង្គបុរេជំនុំជម្រះពន្យល់ថា តើថេរវេលាកំណត់រយៈពេល ៣០ថ្ងៃ ដូចដែលមានចែងក្នុងវិធាន៧៥នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក (វិធានផ្ទៃក្នុង)នោះ គឺសំដៅទៅលើថេរវេលាកំណត់សម្រាប់ដាក់សារណាឧទ្ធរណ៍ទាំងមូល ឬគ្រាន់តែជាថេរវេលាកំណត់សម្រាប់ការប្រកាសជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះមិនធ្វើការបកស្រាយលើវិធានទាំងនេះជាទូទៅទេ លើកលែងតែមានការចាំបាច់ត្រូវបកស្រាយដោយសារមានការតវ៉ាពីភាគី ឬផលវិបាកផ្សេងៗដែលអាចកើតមានឡើងពីការមិនបានបកស្រាយវិធានទាំងនេះ។ ប៉ុន្តែក្នុងករណីនេះ ភាពស្រពិចស្រពិលក្នុងការបកស្រាយវិធានលែងជាបញ្ហាហើយ នៅពេលដែលអង្គបុរេជំនុំជម្រះបានទទួលយកការប្រកាសអំពីបណ្តឹងឧទ្ធរណ៍។

## ជំពូក ៣ - ប្រភេទនៃបណ្តឹងឧទ្ធរណ៍

៦. សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានធ្វើឡើងដោយអនុលោមតាមវិធាន៦៣(២)នៃវិធានផ្ទៃក្នុង ដែលបើកផ្លូវឧទ្ធរណ៍ស្របតាមវិធាន៦៣(៤)នៃវិធានផ្ទៃក្នុងនេះទៅអង្គបុរេជំនុំជម្រះ។ ប្រភេទនៃបណ្តឹងឧទ្ធរណ៍នេះមិនមានចែងក្នុងវិធានផ្ទៃក្នុងទេ។ ដូច្នោះហើយ អង្គបុរេជំនុំជម្រះត្រូវតែសម្រេចថា តើត្រូវពិនិត្យការឃុំខ្លួនបណ្តោះអាសន្នឡើងវិញម្តងទៀត ឬថាតើអង្គបុរេជំនុំជម្រះជាប់កាតព្វកិច្ចត្រូវពិចារណាតាមហេតុផលដែលមានក្នុងសារណារបស់ភាគីប្តឹងឧទ្ធរណ៍។

៧. ក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើង ក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានអនុម័តកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង") និងច្បាប់ស្តីពីការបង្កើតអ.វ.ត.កក្នុងតុលាការកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី២៧ ខែតុលាឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មិនមានបទប្បញ្ញត្តិជាក់លាក់ណាមួយចែងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតឡើយ។ មាត្រា១២.១ នៃកិច្ចព្រមព្រៀងចែងយ៉ាងច្បាស់ថា [illegible]



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00154262

C5/45

លោមតាមច្បាប់កម្ពុជា។ ដោយឡែក វិធានផ្ទៃក្នុងមានចែងជាបទប្បញ្ញត្តិច្បាស់លាស់ក្នុងការផ្តល់សិទ្ធិឱ្យប្តឹងឧទ្ធរណ៍លើដីកាឃុំខ្លួនបណ្តោះអាសន្ន ដោយដឹងថាក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[១] នៃព្រះរាជាណាចក្រកម្ពុជាមានចែងអំពីបទប្បញ្ញត្តិទាក់ទងនឹងសភាស៊ើបសួរ។ អង្គបុរេជំនុំជម្រះបំពេញតួនាទីជាសភាស៊ើប-សួរនេះនៅក្នុងអ.វ.ត.ក។ ដូច្នេះ របៀបដែលអង្គបុរេជំនុំជម្រះដោះស្រាយបណ្តឹងឧទ្ធរណ៍លើដីកាឃុំខ្លួនបណ្តោះអាសន្ននោះ គឺអនុវត្តតាមនីតិវិធី ដូចមានចែងក្នុង"គន្ថីទី៤ ការស៊ើបសួរ មាតិកាទី២ សភាស៊ើបសួរ"។

**មាត្រា ២៦១** (ការពិនិត្យលើនិយ័តភាពនៃនីតិវិធី)

*នៅរាល់ពេលដែលបានទទួលបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនីយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តិទៅដ៏ល្អនៃនីតិវិធីនេះ។*

*កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ។*

*សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា២៨០(អានុភាពនៃមោឃកម្ម) នៃក្រមនេះ។*

**មាត្រា ២៦២** (កិច្ចនៃការស៊ើបសួរបន្ថែម)

*សភាស៊ើបសួរអាចបង្គាប់ឲធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍។*

*ដើម្បីបំពេញកិច្ចនេះ សភាស៊ើបសួរត្រូវចាត់តាំងសមាជិកម្នាក់របស់សភា ឬក៏ចៅក្រមស៊ើបសួរម្នាក់ដែលខ្លួនប្រគល់អំណាចឱ្យ។*

*ចៅក្រមដែលទទួលភារកិច្ចស៊ើបសួរបំពេញនោះ ប្រើប្រាស់អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងព្រំដែនកំណត់ដោយសភាស៊ើបសួរ។*

*កាលណាកិច្ចស៊ើបសួរត្រូវបានបំពេញរួចហើយ សំណុំរឿងនៃនីតិវិធីត្រូវយកមកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។*

---

[១] ក្រមនេះនៅជាសេចក្តីព្រាងនៅឡើយនៅពេលវិធានផ្ទៃក្នុងត្រូវបានអនុម័ត។ ក្រមនេះត្រូវបានឡាយព្រះហត្ថលេខា[illegible] ព្រះមហាក្សត្រនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងចូលជាធរមាននៅទីក្រុងភ្នំពេញកាលពីថ្ងៃទី២០ ខែសីហា [illegible] ក្រមនេះមានតែជាភាសាខ្មែរ និងភាសាបារាំងប៉ុណ្ណោះ។

---

រឿងក្តី កាំង ហ្កេកអ៊ាវ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00154263

C5/45

*ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការថ្មី។ បទប្បញ្ញត្តិនៃមាត្រា២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា)នៃក្រមនេះត្រូវយកមកអនុវត្ត។*

៨. បើអានវិធានផ្ទៃក្នុង និងមាត្រាទាំងនេះក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ អង្គបុរេជំនុំជម្រះត្រូវពិនិត្យឡើងវិញលើដីកាឃុំខ្លួនបណ្ដោះអាសន្ន ដោយពិនិត្យមើលលើ៖

ក. នីតិវិធីទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតមុនពេលចេញដីកា

ខ. ការប្រើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលនាំទៅដល់ការពិចារណាលើការអនុវត្តវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

គ. ភាពគ្រប់គ្រាន់នៃអង្គហេតុដើម្បីទាញសេចក្ដីសន្និដ្ឋានតាមវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង

ឃ. តើកាលៈទេសៈដែលប្រើជាមូលដ្ឋានក្នុងការចេញដីកាឃុំខ្លួនបណ្ដោះអាសន្ននៅមានអត្ថិភាពនៅឡើយឬ នាពេលបច្ចុប្បន្ននេះ និង

ង. បញ្ហាដទៃផ្សេងទៀតដែលមិនទាន់បានដោះស្រាយនិងកម្មវត្ថុនៃមូលហេតុចម្បងៗនៃបណ្ដឹងឧទ្ធរណ៍

**ជំពូក ៤ - ការពិនិត្យលើនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតមុនការចេញដីកា**

៩. អង្គបុរេជំនុំជម្រះបានពិនិត្យថា តើសហចៅក្រមស៊ើបអង្កេតបានរំលឹកដល់ជនត្រូវចោទអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយទៅនឹងសំណួរនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីដែរឬអត់ ដូចមានចែងក្នុងវិធាន ២១(១)(ឃ) ដែលវិធាននោះចែងថា៖

*ជនណាដែលត្រូវបានសង្ស័យឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់មកលើខ្លួននិងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្ដល់ព័ត៌មានដល់ខ្លួនពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប*[២]។

[២] វិធានផ្ទៃក្នុងនេះស្របតាមមាត្រា៣៥ (ថ្មី) នៃច្បាប់អ.វ.ត.ក



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

១០. យើងឃើញច្បាស់ថាជនត្រូវចោទត្រូវបានគេប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប តែនៅពេលចាប់ផ្តើមសវនាការបឋមដែលគាត់បានចូលរួមតែប៉ុណ្ណោះ។ គាត់មិនត្រូវបានគេប្រាប់អំពីសិទ្ធិនេះ នៅមុនពេលសវនាការតទល់គ្នា ឬការសួរយកចម្លើយណាមួយទេ។ បន្ទាប់ពីមានសំនួរលើកឡើងនៅក្នុងសវនាការអង្គបុរេជំនុំជម្រះ សហមេធាវីរបស់ជនជាប់ចោទបានជម្រាបអង្គបុរេជំនុំជម្រះថា សហមេធាវីពិចារណាថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប“នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី។ សហមេធាវីបានពិចារណាថា ជនត្រូវចោទត្រូវបានគេប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅពេលចូលខ្លួនដំបូងនៅមុខសហចៅក្រមស៊ើបអង្កេត ដែលដំណាក់ការនេះជាដំណាក់ការចាប់ផ្តើមការ“ស៊ើបអង្កេត”។ ចំនុចនេះចោទជាបញ្ហាឡើងថា តើឃ្លាថា “នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី” មានន័យយ៉ាងដូចម្តេច ប្រសិនបើសហមេធាវីរបស់ជនត្រូវចោទមិនប្រាប់អង្គបុរេជំនុំជម្រះអំពីបញ្ហានេះ។ សហមេធាវីមានវត្តមាននៅក្នុងសវនាការ និងនៅក្នុងពេលសួរយកចម្លើយនីមួយៗ ហើយជនត្រូវចោទនោះក៏បានដឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបក្នុងពេលសវនាការ និង ការសួរយកចម្លើយនីមួយៗដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជនត្រូវចោទបានអនុវត្តសិទ្ធិនេះក្នុងពេលសវនាការ និងការសួរយកចម្លើយ ហើយជនត្រូវចោទក៏បានស្ម័គ្រចិត្តផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរជូនទៅសហចៅក្រមស៊ើបអង្កេតផងដែរ។ បន្ទាប់ពីអង្គបុរេជំនុំជម្រះបានសួរសំណួរ សហមេធាវីក៏បានបញ្ជាក់ច្បាស់ផងដែរថា ដោយពិចារណាជំហរដែលពួកគេបានលើកឡើងពីមុន សហមេធាវីនឹងមិនស្នើសុំឲ្យមោឃៈភាពនៃកិច្ចដំណើរការនីតិវិធីដោយសារបញ្ហានេះឡើយ។ ដូច្នេះហើយ អង្គបុរេជំនុំជម្រះយល់ថាជនត្រូវចោទ បានបោះបង់ចោលសិទ្ធិក្នុងការតវ៉ាអំពីកំហុសផ្នែកនីតិវិធី។ ដោយពិចារណាលើកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថាមិនមានប្រយោជន៍អ្វីត្រូវធ្វើការជំនុំជម្រះលើបញ្ហាទាក់ទងនឹងអត្ថន័យនៃឃ្លាដែលសរសេរថា “នៅគ្រប់ដំណាក់ការនៃនីតិវិធី គេត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប” ដូចមានចែងក្នុងវិធាន២១(១)(ឃ)ទៀតនោះទេ។

១១. អង្គបុរេជំនុំជម្រះបានបន្តពិនិត្យបន្ថែមទៀត ថាតើជនត្រូវចោទមានមេធាវីការពារក្តីតាមជម្រើសរបស់ខ្លួន ដូចដែលមានចែងក្នុងវិធាន២១(១)(ឃ)ដែរឬទេ? ក្នុងកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត ជនត្រូវចោទបានបញ្ជាក់ច្បាស់ថាខ្លួនត្រូវការជំនួយពីមេធាវីអន្តរជាតិ និងមេធាវីជាតិដូចមានចែងក្នុងវិធាន២២។ ទោះបីកំណត់ហេតុនៃសវនាការតទល់គ្នាមិនបានបញ្ជាក់ច្បាស់ក៏ដោយ សហមេធាវីនឹង

រឿងក្តី កាំង ហ្កេកអ៊ាវ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

សហព្រះរាជអាជ្ញាបានបញ្ជាក់ប្រាប់អង្គបុរេជំនុំជម្រះច្បាស់ថា មេធាវីអន្តរជាតិមានវត្តមាននៅពេលនោះ ហើយមេធាវីនោះត្រូវបានអនុញ្ញាតឲ្យការពារជនត្រូវចោទតាមរយៈមេធាវីជាតិ ដូច្នេះហើយសិទ្ធិរបស់ជនត្រូវចោទមិនត្រូវបានរំលោភ ហើយក៏គ្មានការតវ៉ាអ្វីចំពោះបញ្ហានេះដែរ។

១២. ដោយផ្អែកលើការទទួលស្គាល់របស់សហមេធាវី អង្គបុរេជំនុំជម្រះសន្និដ្ឋានថា មិនចាំបាច់បន្តពិចារណាលើបញ្ហាទាំងនេះទៀតឡើយ។

## ជំពូក ៥ - ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលនាំទៅដល់ការពិចារណាដល់ការអនុវត្តវិធាន៦៣(៣)

១៣. សហមេធាវីបានលើកឡើងនូវទឡ្ហីករណ៍ជាច្រើនក្នុងសារណារបស់ខ្លួន ដើម្បីពន្យល់ថាហេតុអ្វីបានជាការឃុំឃាំងជាងប្រាំបីឆ្នាំមុននោះជាការរំលោភទៅនឹងបទប្បញ្ញត្តិនៃច្បាប់កម្ពុជាដែលពាក់ព័ន្ធ និងច្បាប់សិទ្ធិមនុស្សជាធរមាន ដូចមានចែងនៅក្នុងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ)។ សហមេធាវីក៏បានយោងលើយុត្តិសាស្ត្រអំពីទ្រឹស្តីនៃការរំលោភលើដំណើរការនីតិវិធីផងដែរ[៣]។ សហមេធាវីបានដាក់សេចក្តីសន្និដ្ឋានថា រយៈពេលនៃការឃុំខ្លួនមុននេះអាចជាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការដែលទទួលបន្ទុកជំនុំជម្រះរឿងក្តីបច្ចុប្បន្ននេះ។ ក្នុងន័យនេះ សហមេធាវីសន្និដ្ឋានថាការឃុំខ្លួនពីមុននោះមានឥទ្ធិពល រារាំងលើការអនុវត្តឆន្ទានុសិទ្ធិដូចមានចែងក្នុងវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង ដើម្បីការពិចារណាលើដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងកិច្ចដំណើរការនីតិវិធីនៅមុខ អ.វ.ត.ក នេះ។

---

[៣] ស្ថានភាពនៅក្នុងសាធារណរដ្ឋកុងហ្គោ ក្នុងរឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *ថុមម៉ាស លូប៉ើងហ្គា ឌីអ៊ីឡូ (Thomas Lubanga Dyilo)* ICC-០១/០៤-០១/០៦-៥១២ សេចក្តីសម្រេចលើប្តឹងឧទ្ធរណ៍របស់មេធាវីអំពីបញ្ហាយុត្តាធិការរបស់តុលាការ ដោយអនុលោមតាមមាត្រា ១៩(២)(ក)នៃលក្ខន្តិកៈ អង្គបុរេជំនុំជម្រះទី១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ ទំព័រ១០ ។ ស្ថានភាពនៅក្នុងសាធារណរដ្ឋកុងហ្គោ ក្នុងរឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *ថុមម៉ាស លូប៉ើងហ្គា ឌីអ៊ីឡូ (Thomas Lubanga Dyilo)* ICC-០១/០៤-០១/០៦-៧៧២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *ថុមម៉ាស លូប៉ើងហ្គា ឌីអ៊ីឡូ (Thomas Lubanga Dyilo)* លើសេចក្តីសម្រេចអំពីបញ្ហាយុត្តាធិការរបស់តុលាការ ដោយអនុលោមតាមមាត្រា ១៩(២)(ក)នៃលក្ខន្តិកៈ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៦។ រដ្ឋអាជ្ញាតទល់នឹង *ដ្រាហ្គាន នីកូលីក (Dragan Nikolic),* IT-94-2-PT, សេចក្តីសម្រេចលើប្តឹងឧទ្ធរណ៍របស់មេធាវីចំពោះការអនុវត្តយុត្តាធិការរបស់សាលាក្តី អង្គជំនុំជម្រះសាលាដំបូងទី២ ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០២ កថាខណ្ឌ១១៤-១១៥។ រដ្ឋអាជ្ញាតទល់នឹង *(បារ៉ាយ៉ាងវីហ្សា Barayagwiza)* ICTR-97-AR72 [illegible] អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ៧៣ និង៧៧។

សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹង ទឡ្ហីករណ៍ទាំងនេះដូចដែលបានរៀបរាប់ក្នុងរបាយការណ៍របស់ខ្លួន។ សហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន យល់ឃើញថា ខ្លួនមិនមានសមត្ថកិច្ចពិនិត្យទៅលើនីត្យានុកូលភាពនៃការឃុំខ្លួនពីមុនមកលើជនត្រូវចោទនោះឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របដែលត្រូវពិនិត្យបញ្ហានេះ ដោយខ្លួនយល់ឃើញថានេះគឺជាមូលហេតុជាក់លាក់មួយនៃបណ្ដឹងឧទ្ធរណ៍។

១៤. មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា:

*១. ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មាននរណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយលើកលែងតែមាន ហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។*

*២. ជនណាដែលត្រូវបានចាប់ខ្លួនត្រូវមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់។*

*៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះគឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម។*

*៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវមានសិទ្ធិដាក់ពាក្យបណ្ដឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យាពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់*

*៥. ជនណាដែលបានរងគ្រោះដោយសារការចាប់ខ្លួន ឬឃុំខ្លួនខុសច្បាប់មានសិទ្ធិទាមទារសំណង[៤]។*

---

[៤] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ៩៩៩ UNTS ១៧១ (១៩៧៦)។មាត្រា៩(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានដាក់បញ្ចូលខ្លឹមសារទាំងស្រុងទៅក្នុងមាត្រា ៣៥(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

00154267

C5/45

១៥. បញ្ហាគឺថាតើការបំពេញកិច្ចពីមុនដោយស្ថាប័នតុលាការផ្សេងក្រៅពីអង្គជំនុំជម្រះវិសាមញ្ញ បានបង្កើតជាការរំលោភលើមាត្រាខាងលើនេះ នាំឲ្យមានផលវិបាកចំពោះការធ្វើសេចក្តីសម្រេចរបស់ការិយាល័យនៃ អ.វ.ត.ក ដូចជាសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះដែរឬទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថាខ្លួនអាចពិចារណាលើការរំលោភលើមាត្រានេះបាន នៅពេលណាដែលស្ថាប័នទទួលបន្ទុកលើការរំលោភបំពាននេះជាការិយាល័យរបស់ អ.វ.ត.ក ឬក៏ស្ថាប័នទទួលបន្ទុកនោះបានបំពេញកិច្ចជំនួសការិយាល័យណាមួយរបស់ អ.វ.ត.ក ឬមួយក៏ត្រូវរួមជាមួយការិយាល័យរបស់អង្គជំនុំជម្រះវិសាមញ្ញ។

១៦. ដូច្នេះ បញ្ហានៃការទំនាក់ទំនងរវាងអ.វ.ត.កនិងតុលាការយោធា គឺទាក់ទងទៅនឹងការពិចារណាថាតើសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចជំនុំជម្រះលើបញ្ហានីត្យានុកូលភាពនៃការឃុំខ្លួនពីលើកមុនដែរឬទេ។

១៧. ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចសម្រេច លើការឃុំខ្លួនបណ្តោះអាសន្ននិងដោះលែងឱ្យនៅក្រៅឃុំ ហើយអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទាំងនេះ។ កិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក វិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនបានផ្តល់សមត្ថកិច្ចណាមួយឲ្យសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីធ្វើការជំនុំជម្រះទៅលើបញ្ហាណាមួយដែលពាក់ព័ន្ធនឹងសេចក្តីសម្រេច ឬកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបអង្កេតនៅតុលាការយោធា ឬតុលាការណាមួយផ្សេងក្នុងប្រព័ន្ធតុលាការកម្ពុជាឡើយ។ សមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ និងការិយាល័យដទៃទៀតរបស់អ.វ.ត.កត្រូវបានកម្រិតយ៉ាងច្បាស់ ពោលគឺដោះស្រាយតែទៅលើកិច្ចការដែលស្ថិតនៅក្រោមច្បាប់អ.វ.ត.កតែប៉ុណ្ណោះ។ យើងមិនឃើញមានបទប្បញ្ញត្តិណាមួយ ដែលចែងអំពីការទំនាក់ទំនងរវាងអ.វ.ត.កជាមួយស្ថាប័ន តុលាការដទៃទៀតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាឡើយ។

១៨. អ.វ.ត.ក មានលក្ខណៈជាច្រើនដែលខុសប្លែកពីតុលាការដទៃទៀតនៅកម្ពុជា។ សមាសភាពរបស់អង្គជំនុំជម្រះ រួមមានចៅក្រមជាតិនិងចៅក្រមអន្តរជាតិ។ ជាទូទៅ លក្ខណៈសម្បត្តិនៃការតែងតាំងចៅក្រមអន្តរជាតិមិនដូចគ្នានឹងលក្ខណៈសម្បត្តិនៃការតែងតាំងចៅក្រមជាតិទេ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ថៅក្រមអន្តរជាតិទាំងនោះមិនធ្លាប់បានទទួលការបណ្តុះបណ្តាលទូទៅលើច្បាប់កម្ពុជា ។ ប៉ុន្តែ ពួកគាត់មាន“បទពិសោធន៍ច្រើនក្នុងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស”[៥]។ អ.វ.ត.កបំពេញកិច្ចដោយខ្លួនឯងទាំងស្រុង តាំងពីពេលចាប់ផ្តើមកិច្ចការស៊ើបសួររហូតដល់ការសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងឡាយ។ ដូចនេះ គ្មានតុលាការនៅក្រៅរចនាសម្ព័ន្ធរបស់អ.វ.ត.កណាមួយមានសិទ្ធិសើរើលើសេចក្តីសម្រេចរបស់អ.វ.ត.ក ហើយដូចគ្នានេះដែរ អ.វ.ត.កក៏មិនមាន សិទ្ធិសើរើលើសេចក្តីសម្រេចរបស់តុលាការណាមួយដែលមិនស្ថិតក្នុងរចនាសម្ព័ន្ធរបស់ខ្លួនដែរ។ នៅក្នុងរចនាសម្ព័ន្ធតុលាការព្រហ្មទណ្ឌកម្ពុជា បណ្តឹងឧទ្ធរណ៍ពីតុលាការយោធាត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ហើយបន្ទាប់មកទៅតុលាការកំពូល។

១៩. ក្នុងការអនុវត្តជាក់ស្តែងនិងតាមផ្លូវច្បាប់ អ.វ.ត.កគឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យផងដែរនៅក្នុងរចនាសម្ព័ន្ធតុលាការជាតិ។ ដូច្នេះ អ.វ.ត.កគ្មានសមត្ថកិច្ច វិនិច្ឆ័យលើចំណាត់ការរបស់ស្ថាបនតុលាការផ្សេងទៀយ។ សហព្រះរាជអាជ្ញាបានជូនសំអាងថាកត្តា មួយចំនួនដែលបានសង្ខេបនៅក្នុងរបាយការណ៍បង្ហាញពីឯករាជ្យភាពនេះ ដែលធ្វើឱ្យអ.វ.ត.កក្លាយជាសាលាក្តីពិសេស និងមានចរិកលក្ខណៈអន្តរជាតិ។

២០. នៅក្នុងការសន្និដ្ឋានរបស់ខ្លួន អង្គបុរេជំនុំជម្រះយោងលើសេចក្តីសម្រេចអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការពិសេសនៃប្រទេសសេរ៉ាលេអូននៅក្នុងរឿងក្តី ***រដ្ឋអាជ្ញា តទល់ជាមួយនឹង ឆាលេស ហ្គែងកុស ថាយឡ័រ (Prosecutor Vs Charles Ghankay Taylor)*** ដែលអង្គបុរេជំនុំជម្រះបានធ្វើការពិចារណាថាតុលាការនេះជាតុលាការអន្តរជាតិ ដោយហេតុថា៖ តុលាការនេះបានបង្កើតឡើងដោយសន្ធិសញ្ញា។ ការបង្កើតតុលាការនេះគឺជាការសំដែងឆន្ទៈរបស់សហគមន៍អន្តរជាតិដែលជាផ្នែកឮមួយនៃយន្តការស្វែងរកយុត្តិធម៌អន្តរជាតិ ហើយមានយុត្តាធិការក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ[៦]។

---

[៥] មាត្រា ១០(ថ្មី)នៃច្បាប់អ.វ.ត.ក

[៦] ***រដ្ឋអាជ្ញា តទល់នឹង ឆាលេស ថៃឡឺ (Charles Taylor),*** SCSL-២០០៣-០១-១ “សេចក្តីសម្រេចអំពីអភ័យឯកសិទ្ធិ[illegible] ប្រកាន់” អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ៣៨-៣៩។

00154269 C5/45

២១. ដោយសារតែអ.វ.ត.កមិនមានទំនាក់ទំនងផ្ទាល់ជាមួយតុលាការយោធា អង្គជំនុំជម្រះវិសាមញ្ញមិនមានសមត្ថកិច្ចដោយផ្ទាល់លើការសើរើចំណាត់ការទាំងឡាយរបស់តុលាការយោធា ឬសើរើចំណាត់ការទាំងនោះថាតើវាស្របតាមច្បាប់កម្ពុជាដែរឬទេ។ ដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះមិនឃើញមានភស្តុតាងបង្ហាញថា តុលាការយោធាបានបំពេញកិច្ចជំនួសអ.វ.ត.កក្នុងការឃុំខ្លួនជនត្រូវចោទ ឬគ្មានភស្តុតាងបង្ហាញពីសកម្មភាពត្រូវរួមគ្នារវាងការិយាល័យរបស់អ.វ.ត.កនិងតុលាការយោធាឡើយ[៧]។ នៅពេលសវនាការ សហមេធាវីរបស់ជនត្រូវចោទបានផ្តល់ឯកសារមួយច្បាប់នៅក្នុងសំណុំរឿង ហើយបានលើកឡើងថាឯកសារនេះបានមកពីតុលាការយោធា។ សហមេធាវីមិនបានលាតត្រដាងពីរបៀបដែលឯកសារមួយច្បាប់នេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយតាមការប្រមើលមើលទៅឯកសារមួយច្បាប់នេះ មិនបានផ្តល់ភស្តុតាងពីការជាប់ទាក់ទងរវាងអ.វ.ត.កជាមួយនឹងតុលាការយោធា ឬក៏បានបង្ហាញថាតុលាការយោធានិងអ.វ.ត.កត្រូវរួមគ្នាក្នុងរូបភាពណាមួយ ក្នុងការឃុំខ្លួនជនត្រូវចោទក្នុងរយៈពេលទាំងអស់ ឬក្នុងរយៈពេលណាមួយលើស៨ឆ្នាំ។

២២. តាមការពិត អ.វ.ត.កបង្កើតឡើងបន្ទាប់ពីចៅក្រមទាំងអស់របស់ខ្លួនធ្វើសច្ចាប្រណិធាន កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦។ ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញមិនមានរូបរាងឡើយមុនថ្ងៃនោះ។ ការបំពេញកិច្ចដំបូងរបស់ចៅក្រមទាំងអស់ គឺត្រូវបង្កើតវិធានផ្ទៃក្នុងដែលយកមកធ្វើជាមូលដ្ឋានក្នុងការចោទប្រកាន់។ វិធានទាំងនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គរវាងចៅក្រម នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧។ ដូច្នេះ ការទំនាក់ទំនង ឬការបំពេញកិច្ចរបស់តុលាការ យោធាជំនួសការិយាល័យណាមួយរបស់អ.វ.ត.ក មិនអាចកើតមានឡើងមុនថ្ងៃទាំងនោះឡើយ។ ចំពោះបញ្ហាដែលតុលាការយោធាបានអះអាងថា ចំណាត់ការរបស់ខ្លួនមួយចំនួនបានធ្វើឡើងដោយផ្អែកលើ ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក មុនពេលដែលច្បាប់នេះមិនទាន់បានធ្វើវិសោធនកម្ម និងក្រោយពេល វិសោធនកម្មរួចហើយនោះក្តី ចំណាត់ការទាំងនោះមិនបានធ្វើឡើងតាមការបង្គាប់របស់អ.វ.ត.កទេ។

២៣. ដោយផ្អែកលើមូលហេតុខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថាសហចៅក្រមស៊ើបអង្កេតអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដូចមានចែងក្នុងវិធាន៦៣(៣) ដូចដែលខ្លួនបានធ្វើ។

---

[៧] សូមអាន *បារាយ៉ាងវីហ្សា (Barayagwiza)* **តទល់នឹង** ***រដ្ឋអាជ្ញា*** "សេចក្តីសម្រេច" កថាខណ្ឌ ៦១ និង *លូបាង់ហ្គា (Lubanga)* ស្តីពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីអំពីការឃុំខ្លួន កថាខណ្ឌ ៤២ ដូចលើកឡើងនៅក្នុងចំនុច៣ខាងលើ។

---



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

២៤. អង្គបុរេជំនុំជម្រះសង្កេតឃើញទៀតថា សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញារបស់ អ.វ.ត.កបានបំពេញកិច្ចតាមមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ហើយ សហមេធាវីមិនបានជំទាស់ថា សហចៅក្រមស៊ើបអង្កេតខ្លួនឯងបានរំលោភលើមាត្រានេះទេ។

២៥. អង្គបុរេជំនុំជម្រះសង្កេតឃើញទៀតថា តាមការជូនសំអាងរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល អាចសម្រេចថាវាជាការសមស្រប ប្រសិនបើលើកយកបញ្ហានៃឃុំខ្លួនបណ្តោះអាសន្នពីលើកមុន ទោះបីជាស្របច្បាប់ឬមិនស្របច្បាប់ក្តី មកពិចារណានៅក្នុងកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល។ អង្គបុរេជំនុំជម្រះបានសម្គាល់ឃើញថា ទោសអតិបរមាមានចំពោះបទល្មើសដែលជនត្រូវចោទត្រូវបានចោទថាបានប្រព្រឹត្តនោះ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ហើយចាប់តាំងពីពេលមុនមក ជនត្រូវចោទមិនបានធ្វើការតវ៉ាចំពោះការចោទប្រកាន់មកលើខ្លួនឡើយ។ បើនិយាយតែអំពីរយៈពេលនៃការឃុំខ្លួនយើងគួរពិចារណាលើបញ្ហាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងករណីដែលយើងដឹងច្បាស់ថារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននោះ ទំនងជាលើសរយៈពេលនៃការទទួលទោស។

## ជំពូក ៦ ការពិនិត្យលើលក្ខខណ្ឌដែលត្រូវបំពេញតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

២៦. វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងចែងថា:

*សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានតែក្នុងលក្ខខណ្ឌដូចខាងក្រោម:*

*(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ និង*

*(ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បី:*

*(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក។*



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

*(២) ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យបំផ្លាញភស្តុតាង។*

*(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។*

*(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ*

*(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ*

២៧. ដើម្បីសម្រេចថាតើមូលហេតុលើការឃុំខ្លួនបណ្តោះអាសន្នបានបំពេញតាមលក្ខខណ្ឌដែរ ឬអត់ ដូចមានចែងនៅក្នុងវិធាន៦៣(៣) អង្គបុរេជំនុំជម្រះបានធ្វើការពិចារណាលើសារណាជាលាយលក្ខណ៍អក្សរនិងដោយផ្ទាល់មាត់ ភស្តុតាងដែលទទួលបានពីភាគីទាំងពីរ និងសំណុំរឿងទាំងមូលរបស់សហចៅក្រមស៊ើបអង្កេតរហូតមកទល់ថ្ងៃសវនាការ។

### ក. <u>មានហេតុផលគ្រប់គ្រាន់ជឿថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង)</u>

២៨. ជនត្រូវចោទមិនបានធ្វើការប្រកែកលើការលើកឡើងថា ខ្លួនជាអនុប្រធាននិងក្រោយមកជាប្រធានមន្ទីរ ស-២១ ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ នៅក្នុងសវនាការថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ សហមេធាវីជាតិលោក ការ សាវុត្ថ បានណែនាំខ្លួនគាត់នៅក្នុងពេលសវនាការដូចតទៅ: “ខ្ញុំ ការ សាវុត្ថ ជាមេធាវីការពារជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានមន្ទីរ ស-២១។

២៩. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីមិនបានតវ៉ាលើករណីដែលថាមានហេតុផលគ្រប់គ្រាន់ជឿថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលសហចៅក្រមស៊ើបអង្កេតកំពុងធ្វើការស៊ើបអង្កេតលើជននោះ ក្នុងតួនាទីជាអ្នកដឹកនាំចាត់ចែងមន្ទីរសន្តិសុខ ស-២១ ក្នុងចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ ដែលនៅពេលនោះ គេចោទថានៅក្រោមអំណាចរបស់គាត់ ការរំលោភបំពានរាប់មិនអស់បានកើតឡើងចំពោះប្រជាជនស៊ីវិលក្នុងន័យទូទៅ រួមមានការសម្លាប់រង្គាល ការឃុំខ្លួនតាមទំនើងចិត្តនិងទារុណកម្មដែលកើតឡើងក្នុងបរិបទនយោបាយមួយគឺការរំលោភជាលក្ខណៈប្រព័ន្ធ និងទ្រង់ទ្រាយធំដោយចាត់បញ្ចូលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា លក្ខខណ្ឌ នៃវិធាន៦៣(៣)(ក) មានគ្រប់គ្រាន់។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. ទំព័រ ១៣

## ខ. <u>ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់</u>

*(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ និង ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យបំផ្លាញភស្តុតាង។ (វិធាន ៦៣(៣)(ខ)(១) និង (២))*

៣០. មូលហេតុលើការឃុំខ្លួនបណ្តោះអាសន្នទាំងពីរនេះត្រូវបានយកមកវិភាគរួមគ្នា ពីព្រោះមានទទ្បីករណ៍គាំទ្រលើមូលហេតុទាំងពីរនេះដូចគ្នា។ តាមការពិត ចម្លើយរបស់សាក្សីអំពីព្រឹត្តិការណ៍នៅក្នុងមន្ទីរ ស-២១ អាចយកមកធ្វើជា“ភស្តុតាង” តាមអត្ថន័យនៅក្នុងវិធាន៦៣(៣)(ខ)(២)នៃវិធានផ្ទៃក្នុង។

៣១. តាមការឆ្លើយរបស់ជនត្រូវចោទខ្លួនឯង មន្ទីរ ស-២១ គឺជាមន្ទីរសន្តិសុខ ដែលប្រត្តិបត្តិការងារប្រមូលចម្លើយសារភាពពីជនជាប់ឃុំ ដែលចម្លើយសារភាពទាំងនោះត្រូវបានគេបញ្ជូនទៅគណៈមជ្ឈិមបក្ស[៨]។ តាមការយល់ទូទៅ មនុស្សជាច្រើនត្រូវបានគេសម្លាប់នៅក្នុងមន្ទីរនេះ ហើយបើយោងតាមសហព្រះរាជអជ្ញាមានសាក្សីតែប៉ុន្មាននាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត។

៣២. សាក្សីដែលរស់រានមានជីវិត មិនថាអ្នកទោស ឬ បុគ្គលិក សុទ្ធតែបានធ្លាប់ឆ្លងកាត់របបដែលសាហាវ និងគួរឱ្យភ័យរន្ធត់នេះ។ សាក្សីមួយចំនួននេះ បាននិយាយជាសាធារណៈអំពីអារម្មណ៍ភ័យខ្លាចរបស់ពួកគេដែលឃើញមាននៅគ្រប់ទីកន្លែង ខណៈពួកគេបំរើការងារជាឆ្មាំគុកនៅក្រោមការគ្រប់គ្រងរបស់ជនត្រូវចោទនៅមន្ទីរ ស-២១[៩]។ តាមការប្រមើលមើលទៅការភ័យខ្លាចនេះនឹងរើឡើងវិញ ហើយនឹងរារាំងសាក្សីទាំងនោះមិនអោយផ្តល់ចម្លើយក្នុងតុលាការ ប្រសិនបើជនត្រូវចោទត្រូវបានដោះលែង មែននោះ។ នៅក្នុងបរិបទជាក់លាក់នៃព្រឹត្តិការណ៍ដែលកើតមាននៅមន្ទីរ ស-២១ ត្រឹមតែឃើញជនត្រូវ ចោទមានវត្តមាននៅក្នុងសង្គមនោះ វាអាចជាការគាបសង្កត់ដល់សាក្សី និងអាចរារាំងពួកគេមិនអោយចម្លើយនៅក្នុងតុលាការបាត់ទៅហើយ។

---

[៨] *នីក ដាន់លប (Nic Dunlop) ឌីឡូសអ៊ិកគ្យូស៊ិនណឺ (The Lost Excutioner) -រឿងរ៉ាវអំពីខ្មែរក្រហម* [ប្លូមប៊ឺរី (Bloomsbury) ២០០៥] ទំព័រ២៧៤ [“*ឌីឡូសអ៊ិកគ្យូស៊ិនណឺ” (“The Lost* Excutioner”)]។

[៩] អៀម៉េងទ្រី (EA Meng-Try និង SIM Sorya (ស៊ឹម សូរិយា) *វីកធីម និង ផឺផេតត្រេតទ័រ (Victims and Perpetrators)-សក្ខីកម្មរបស់កម្មាភិបាលខ្មែរក្រហមវ័យក្មេងមួយរូប* ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០១ ទំព័រ៣៥។

៣៣. តាមបរិបទទូទៅជាងនេះ ការសិក្សាអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងចំណោមសាក្សីសំខាន់ៗ និងអ្នកតំណាងផ្លូវការនៅក្នុងខេត្តតាកែវ បានបង្ហាញឱ្យឃើញថាក្នុងចំណោមមូលហេតុផ្សេងៗ សាក្សីសំខាន់ៗមួយចំនួនបានសំដែងការភ័យខ្លាចអំពីការផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដោយផ្អែកលើសម្អាងថា ពួកគេមានការភ័យខ្លាចនឹងជនត្រូវចោទទាំងឡាយ ឬ សាច់ញាតិរបស់ជនទាំងនោះ អាចដាក់សម្ពាធ ឬសងសឹកលើពួកគេ[១០]។ ចំនុចនេះគួរយកមកពិចារណានៅក្នុងបរិបទសង្គមដែលនៅតែកើតមាននៅក្នុងប្រទេសកម្ពុជាដោយវិធានការការពារសាក្សីអាចនៅមានកម្រិត ហើយអាវុធអាចងាយស្រួលរកបាន។ ដូច្នេះ ឆន្ទៈរបស់សក្សីក្នុងការមកចូលរួមផ្តល់ចម្លើយនៅក្នុងតុលាការ គឺនៅមានភាពទន់ខ្សោយបាត់ទៅហើយ ហើយឆន្ទៈនោះទៀតសោតនឹងកាន់តែទន់ខ្សោយថែមទៀត ប្រសិនបើដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំមែននោះ។

៣៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជនត្រូវចោទបានធ្វើការគម្រាមកំហែងកាលពីអតីតកាល ក្នុងគោលបំណងធានាថា សកម្មភាពរបស់គាត់នៅមន្ទីរ ស-២១ មិនត្រូវបានគេយកមកលាតត្រដាង។ នៅក្នុងការសម្ភាសន៍មួយ អតីតកម្មាភិបាលខ្មែរក្រហមមួយរូបគឺ **ចិក ស៊ីម** បាននិយាយថា ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ជនត្រូវចោទបានព្រមានរូបលោកថា ប្រសិនបើរូបលោកនិយាយជាមួយនរណាម្នាក់ពីការពាក់ព័ន្ធរបស់គាត់ទៅនឹងមន្ទីរសន្តិសុខ ស-២១ ជនត្រូវចោទនឹងរាយការណ៍ទៅ **អៀង សារី** ឱ្យសម្លាប់គាត់[១១]។ នេះបង្ហាញជាសញ្ញាថា ជនត្រូវចោទអាចធ្វើការគម្រាមកំហែងនេះជាថ្មីម្តងទៀត ដើម្បីបំភិតបំភ័យដល់សាក្សី។

៣៥. អង្គបុរេជំនុំជម្រះមិនបានឃើញមានការតវ៉ាដែលថា ក្នុងបច្ចុប្បន្នភាព ជនត្រូវចោទបានឃើញសំណុំរឿងទាំងមូល ដែលក្នុងនោះរួមមានឈ្មោះសាក្សីសំខាន់ៗ។ ជនត្រូវចោទបានអះអាងថា គាត់គ្មានហេតុផលអ្វីទៅគាបសង្កត់សាក្សីឡើយ ពីព្រោះមេធាវីបានលើកឡើងថា សហចៅក្រមស៊ើប

---

[១០] ហ្គៀ តេគេ ជេនសេន (Geerteke JANSEN) វយអូហ្វតាកែវ (Voice of Takeo)-*ការវាយតម្លៃសាកល្បងមួយអំពីការភ័យខ្លាចលើបុគ្គល ដែលអាចជាសាក្សីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា ខែតុលា ឆ្នាំ២០០៦)។

[១១] កិច្ចសម្ភាស ចិក ស៊ីម (Chek Sim) ដែលសម្ភាសដោយលោក យ៉ា អូស្មាន (Ysa Osman) ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ ខេត្តកំពង់ឆ្នាំង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.* C.E.C.C. ទំព័រ ១៥

អង្កេតបានធ្វើការសួរយកចម្លើយពីសាក្សីទាំងអស់នោះរួចហើយ។ ទោះបីជាសាក្សីទាំងអស់នោះបានផ្ដល់ចម្លើយ និង ផ្ដល់ភស្ដុតាងរួចហើយក៏ដោយ សាក្សីទាំងអស់នោះនៅតែមានឱកាសចូលមកផ្ដល់ចម្លើយ ក្នុងពេលស៊ើបអង្កេតបន្ថែម នៅពេលក្រោយ និង/ឬ នៅពេលសវនាការ។

៣៦. បន្ថែមលើចំនុចនេះ សក្ខីកម្មទាំងឡាយរបស់សាក្សីមួយចំនួនតូចអំពីព្រឹត្តិការណ៍នៅមន្ទីរ ស-២១ មានសារៈសំខាន់ខ្លាំងណាស់ចំពោះការស៊ើបអង្កេត និង ជាពិសេសនៅលើកចុងក្រោយ ក្នុងពេលធ្វើការជំនុំជម្រះ។ វាជាការចាំបាច់ណាស់ដែលសាក្សីទាំងនោះមិនស្ថិតនៅក្នុងសភាពភ័យខ្លាច ឬឈឺចាប់ពីសម្ពាធណាមួយដែលនាំឱ្យពួកគេនឹងមិនមកផ្ដល់ចម្លើយនៅក្នុងតុលាការ។
អង្គបុរេជំនុំជម្រះយល់ថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានការចាំបាច់ក្នុងការទប់ស្កាត់ជនត្រូវចោទមិនអោយគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្ដុតាង។

*(២) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី(វិធាន៦៣(៣)-ខ(៣)*

៣៧. ពីឆ្នាំ១៩៧៩ដល់១៩៩៩ ជនត្រូវចោទគេចខ្លួនពីសាធារណៈជន រហូតដល់ពេលចាប់ខ្លួនដោយតុលាការយោធា។ ខណៈពេលដែលព័ត៌មានលម្អិតអំពីលំនៅដ្ឋាន និងឈ្មោះដែលគាត់បានប្រើមិនច្បាស់លាស់ មានកត្តាជាច្រើនបង្ហាញថា ជនត្រូវចោទបានប្រើប្រាស់វិធានការផ្សេងៗដើម្បីបិទបាំងពីអតីតកាលរបស់គាត់ និងចៀសវាងមិនឲ្យគេស្គាល់ខ្លួនថាជាឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១៖

-ពីឆ្នាំ១៩៨៦ គាត់ប្រើឈ្មោះ ហាំង ពិន

-គាត់ប្ដូរឈ្មោះមុខរបរជាញឹកញាប់ ដូចជាធ្វើជាគ្រូបង្រៀន នាយកសិក្សា និងអ្នកជំនួយផ្នែកពេទ្យ[១២]

-ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនបានត្រឡប់ទៅរស់នៅក្នុងស្រុកកំណើតវិញទេ ប៉ុន្តែបែរទៅជារស់នៅផ្លាស់ពីមួយកន្លែងទៅមួយកន្លែងទៀត ជាពិសេសនៅក្នុងតំបន់ត្រួតត្រា

[១២] សេត ម៉ៃដានស៍ (Set MYDANS), "អ្នកធ្វើទារុណកម្មរបបខ្មែរក្រហមផ្លាស់ប្ដូរសាសនា មានអារម្មណ៍ថាជីវិតរបស់គាត់ដូច សាំង ផូល (St. Paul)", ឌីសៀតថលថែម (The Seattle Time), ថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩៩។ *ឌីឡូសអុិកគ្ស៊ិបឃើ (The Lost Excutioner)* ទំព័រ២៥២-២៥៣, ២៧០-២៧៩; ចនឌីស៊ីអូសៀរី និង កុក ថៃអេង (John D. CIORCIARI and Kok-Thay ENG) "ម្ដាយរបស់ឌុចៈ គ្រួសារភ័យខ្លាចអំពីសុវត្ថិភាពរបស់ប្រធានមន្ទីរ (ស-២១) ទួលស្លែង", ស្វែងរកការពិត, ទំព័រ៣៦ (ម្ដាយរបស់ឌុច)។



E.C.C.C. P.T.C. * CHAMBER CHAMBRE PRÉLIMINAIRE *

00154275

C8/45

ដោយខ្មែរក្រហមនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា តំបន់សំឡូត និងជំរុំជនភៀសខ្លួនឈ្មោះ បាន ម៉ាមួង ក្នុងប្រទេសថៃ[១៣]

-គាត់បានសរសេរព័ត៌មានមិនពិត នៅក្នុងប្រវត្តិរូបសង្ខេបរបស់អត្តសញ្ញាណប័ណ្ណរបស់គាត់ ឧទាហរណ៍: គាត់កើតនៅភូមិអាចារ្យលិច ខេត្តកំពង់ធំ និងថាម្តាយរបស់គាត់ស្លាប់[១៤] និង

-គាត់មិនបានទៅសួរសុខទុក្ខគ្រួសាររបស់គាត់ពីឆ្នាំ១៩៧៩ ដល់១៩៩៦ ដូចនេះហើយម្តាយរបស់គាត់ជឿថាគាត់បានស្លាប់បាត់ទៅហើយ[១៥]។

៣៨. ក្នុងខែមេសា ឆ្នាំ១៩៩៩ ជនត្រូវចោទ ត្រូវបានរកឃើញដោយអ្នកកាសែតពីររូប នៅក្នុងស្រុកសំឡូត[១៦]។ នៅពេលអត្ថបទនៃការរកឃើញរូបគាត់ និងការឆ្លើយសារភាព បានត្រូវផ្សព្វផ្សាយជាសាធារណៈ គាត់បានគេចខ្លួនបាត់[១៧]។

៣៩. ឥឡូវនេះ ការប្រឈមនឹងភាពដែលអាចទទួលការផ្តន្ទាទោសដាក់គុកអស់មួយជីវិត គឺមានហានិភ័យមួយដែលថាគាត់នឹងគេចខ្លួនបាត់ម្តងទៀត។ លើសពីនេះទៅទៀត ក្នុងករណីដែលថាគាត់នឹងត្រូវបានជំនុំជម្រះជាសាធារណៈនៅចំពោះជនរងគ្រោះនិងញាតិសន្តានរបស់ពួកគេ អំពីបទឧក្រិដ្ឋដែលគាត់ត្រូវបានគេចោទប្រកាន់ នោះអាចជាការលើកទឹកចិត្តដល់គាត់បន្ថែមទៀតឲ្យរត់គេចខ្លួន។

៤០. ចំពោះអង្គហេតុដែលមេធាវីរបស់ជនត្រូវចោទបានលើកឡើងថា ជនត្រូវចោទគ្មានលិខិតឆ្លងដែនមួយច្បាប់សោះ និងថាគាត់ និងគ្រួសាររបស់គាត់ជាអ្នកក្រីក្រ នឹងមិនអាចទប់ស្កាត់គាត់ពីការប៉ុនប៉ងរត់គេចខ្លួនបានឡើយ ប្រសិនបើគាត់ត្រូវបានដោះលែង ឬ គាត់អាចលាក់ខ្លួនជានិរន្តក្នុងប្រទេសកម្ពុជាដូចដែលគាត់បានធ្វើកន្លងមក ឬក៏ឆ្លងដែនដោយខុសច្បាប់។

---

[១៣] *ឌីឡុសអ៊ិកឝ្យូស៊ិនណឺ (The Lost Excutioner)* ទំព័រ២៥២-២៥៣, "ម្តាយរបស់ឌុចៈ", ទំព័រ៣៦-៣៧

[១៤] *ឌីឡុសអ៊ិកឝ្យូស៊ិនណឺ (The Lost Excutioner)* ទំព័រ២៥២

[១៥] "ម្តាយរបស់ឌុច" ទំព័រ៣៦

[១៦] *ឌីឡុសអ៊ិកឝ្យូស៊ិនណឺ (The Lost Excutioner)*" ទំព័រ២៧០-២៧៨

[១៧] *ឌីឡុសអ៊ិកឝ្យូស៊ិនណឺ (The Lost Excutioner)*"ទំព័រ២៧៨

៤១. ដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាវិធានការមួយដ៏ចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី។

*(3) ការពារសុវត្ថិភាពរបស់ជនត្រូវចោទ (វិធានផ្ទៃក្នុង វិធាន៦៣-៣ (ខ)-(៤))*

៤២. តាំងពីពេលរកឃើញរូបគាត់ដោយអ្នកកាសែតក្នុងឆ្នាំ១៩៩៩មក ជនត្រូវចោទបានផ្ដល់បទសម្ភាសន៍ជាច្រើនដល់អ្នកកាសែត និងដល់អ្នកតំណាងរបស់គណៈកម្មាធិការជាន់ខ្ពស់ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់សហប្រជាជាតិអំពីសកម្មភាពរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងគាត់បានបញ្ជាក់អំពីតួនាទីរបស់គាត់ជាប្រធានមន្ទីរសន្តិសុខ ស-២១ ។ គាត់ប្រាប់អ្នកកាសែតថា គាត់បានត្រៀមរួចជាស្រេចហើយដើម្បីប្រាប់ឲ្យគេដឹងអំពីមេដឹកនាំដទៃទៀត និងបានឲ្យព័ត៌មានលម្អិតជាច្រើនអំពីការរៀបចំរចនាសម្ព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសការកំណត់អត្តសញ្ញាណមេដឹកនាំជាន់ខ្ពស់មួយចំនួន និងមុខងាររបស់ពួកគេ[១៨]។

៤៣. ការគំរាមកំហែងដល់សុវត្ថិភាពរបស់ជនត្រូវចោទ គឺកើតចេញពីជនរងគ្រោះ និងញាតិសន្តានរបស់ពួកគេ និងបុគ្គលិកធ្វើការរបស់គាត់នៅមន្ទីរ ស-២១។ ឥឡូវនេះ ជនត្រូវចោទព្រមទទួលថាខ្លួនធ្លាប់ជាប្រធានមន្ទីរ ស-២១ ដែលនៅទីនោះ អ្នកទោសរាប់ពាន់នាក់ត្រូវបានធ្វើទារុណកម្មមុននឹងសម្លាប់ដោយមធ្យោបាយឃោរឃៅ។ ដូចនេះ ជនរងគ្រោះនិងញាតិសន្តានរបស់ពួកគេ អាចប៉ុនប៉ងស្វែងរកការសងសឹក។ ពួកគេបានទទ្រឹងរង់ចាំយុត្តិធម៌អស់រយៈពេលជាង៣០ឆ្នាំមកហើយ ហើយប្រតិកម្មរបស់ពួកគេ អាចជាអំពើហិង្សាណាមួយប្រសិនបើពួកគេបានដឹងថាជនត្រូវចោទបានដោះលែងឲ្យមានសេរីភាព ទោះបីជាការដោះលែងឲ្យមានសេរីភាពនេះអាចជាបណ្ដោះអាសន្នក៏ដោយ។

៤៤. មេធាវីរបស់ជនត្រូវចោទបានពោលអះអាងថា ជនត្រូវចោទបានរស់នៅដោយមានសេរីភាពពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៩ និងគ្មានការគំរាមកំហែងណាមួយបានធ្វើឡើងចំពោះសុវត្ថិភាពរបស់គាត់។ នៅពេលគាត់ត្រូវបានរកឃើញដោយអ្នកកាសែត គាត់ខ្លួនឯងបានបញ្ជាក់យ៉ាងច្បាស់អំពីការព្រួយបារម្ភ

---

[១៨] ណេត ថៃយឺ (Nate Thayer) *ហ្វាអ៊ីសថឹន អ៊ីកូណូមីក វ្យូ* (Far Eastern Economic View) ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ "ដេតអ៊ីនឌីធែល(Death in Detail)" (ERN: ០០០៨៧៥១៣-០០០៨៧៥១៤) "ដេតអ៊ីនឌីធែល(Death in Detail)"



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ចំពោះសុវត្ថិភាពរបស់គាត់។ អ្នកកាសែតឈ្មោះ ណេត ថាយយឺ (Nate Thayer) បានដកស្រង់សម្តីរបស់ជនត្រូវចោទដូចខាងក្រោមពីអត្ថបទដែលមានចំណងជើងថា "ខ្ញុំស្ថិតក្នុងគ្រោះថ្នាក់":

*"ខ្ញុំមិនចង់ឲ្យនរណាម្នាក់ដឹងអំពីទំនាក់ទំនងរបស់យើង" គាត់បានប្រាប់ទស្សនាវដ្តី។ "ពួកគេនឹងធ្វើឲ្យខ្ញុំគ្មានសេចក្តីសុខឡើយ។ ខ្ញុំគ្មានការសម្ងាត់អ្វីទេជាមួយទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា ប៉ុន្តែខ្ញុំមានការភ័យខ្លាចចំពោះមនុស្សនៅជុំវិញខ្លួនខ្ញុំ។ ខ្ញុំមិនដឹងថានរណាជាមនុស្សរបស់ខ្លួន ជា នរណាជាមនុស្សរបស់តាម៉ុក នរណាជាមនុស្សរបស់ខៀវ សំផន។ ខ្ញុំស្ថិតក្នុងគ្រោះថ្នាក់។ ជីវិតរបស់ខ្ញុំស្ថិតក្នុងភាពប្រថុយប្រថាន។ (...) ពួកគេអាចសម្លាប់ខ្ញុំ (...)"[១៩]*

៤៥. ក្នុងអត្ថបទមួយទៀតដែលចេញផ្សាយក្នុងថ្ងៃដដែល អ្នកកាសែតឈ្មោះ ណេត ថាយយឺ (Nate Thayer) បានរាយការណ៍ថា:

*ឥឡូវអតីតកាលរបស់គាត់បានត្រូវបង្ហាញឲ្យដឹង ខុចច្បាស់ជាព្រួយបារម្ភអំពីជីវិតរបស់គាត់។ ជួនកាលគាត់និយាយខ្សឹបៗចំពោះឈ្មោះមេដឹកនាំខ្មែរក្រហម ដោយបង្កើបឲ្យដឹងតែអក្សរដើមនៃឈ្មោះប៉ុណ្ណោះ ធ្វើដូចនេះអ្នកដែលស្តាប់ឮមិនអាចស្គាល់អំពីឈ្មោះរបស់ពួកគេ។ នៅថ្ងៃមួយទៀត គាត់សូមឲ្យបើកឡានទៅកន្លែងឆ្ងាយដាច់ពីគេដើម្បីនិយាយក្នុងឡានកុំឲ្យគេអាចស្តាប់ឮបាន[២០]។*

៤៦. អង្គការសហប្រជាជាតិ និងអង្គការលើកលែងទោសអន្តរជាតិ ក៏បានសម្តែងការព្រួយបារម្ភរបស់ខ្លួនចំពោះសុវត្ថិភាពរបស់ជនត្រូវចោទនៅពេលនោះដែរ តាំងពីពេលសម្ភាសន៍ ជនត្រូវចោទបានប្រាប់ឲ្យគេដឹងអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួកមេដឹកនាំខ្មែរក្រហម។ អង្គការលើកលែងទោសអន្តរជាតិ បានចេញផ្សាយអត្ថបទមួយដែលមានចំណងជើងថា "សកម្មភាពជាបន្ទាន់" នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៩ ដែលក្នុងអត្ថបទនោះបានលើកឡើងថា "ជនត្រូវចោទអាចត្រូវបានសម្លាប់

---

[១៩] ណេត ថាយយឺ (Nate Thayer) *ហ្វាអ៊ីសថឺន អ៊ីកូណូមីក វ្យូ* (Far Eastern Economic View) ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩ "ខ្ញុំស្ថិតក្នុងគ្រោះថ្នាក់" (ERN: ០០០៨៧៥១៣-០០០៨៧៥១៤) "ខ្ញុំស្ថិតក្នុងគ្រោះថ្នាក់" ទំព័រ១។ សូមអានផងដែរ *ឃាតករដែលបាត់ខ្លួន (The Lost Excutioner)* ទំព័រ២៧០-២៧៨

[២០] "ដេតអ៊ីនឌីតែល(Death in Detail)" ទំព័រ៣-៤

ដើម្បីកុំឲ្យគាត់ផ្តល់សក្ខីកម្មប្រឆាំងនឹងអ្នកដទៃទៀត ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ”[២១]។

៤៧. អង្គបុរេជំនុំជម្រះ រកមិនឃើញនូវព័ត៌មានពាក់ព័ន្ធដែលថាការគំរាមកំហែងដល់សុវត្ថិភាពរបស់ជនត្រូវចោទបានថយចុះក្នុងរយៈពេលកន្លងមកនេះ។ ឥឡូវនេះ អត្តសញ្ញាណរបស់ជនត្រូវចោទបានត្រូវផ្សព្វផ្សាយជាសាធារណៈ សុវត្ថិភាពរបស់គាត់គឺស្ថិតក្នុងភាពគ្រោះថ្នាក់ជាងពេលណាៗទាំងអស់។

៤៨. ពីព្រោះតែប្រភេទនៃសាលដីកានេះ ការអនុវត្តទៅតាមស្មារតីរួមគឺជាហេតុផលមួយដ៏សមស្រប។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដ៏ចាំបាច់ដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ។

(៤) ការរក្សាសណ្តាប់ធ្នាប់សាធារណៈ (*វិធាន៦៣(៣)-ខ(៥)*)

៤៩. ប្រជាជនខ្មែរប្រហែលជា ១.៧លាននាក់ បានស្លាប់ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានដឹកនាំប្រទេស។ ចំនួននេះប្រហែលជាមួយភាគបួន នៃចំនួនប្រជាជនទាំងអស់នាពេលនោះ។ ប្រជាជនខ្មែរភាគច្រើនក្នុងពេលបច្ចុប្បន្ននេះ មិនត្រឹមតែជាអ្នកធ្លាប់រស់នៅក្រោមរបបឃោរឃៅរបស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែបានបាត់បង់ញាតិសន្តាន និងមិត្តភ័ក្តិមួយឬច្រើននាក់។

៥០. ផ្ទុយពីអ្វីដែលមេធាវីរបស់ជនត្រូវចោទបានលើកឡើង អង្គបុរេជំនុំជម្រះយល់ឃើញថា ពេលវេលាកន្លងផុតទៅមិនបានកាត់បន្ថយផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យលើសង្គមកម្ពុជាឡើយ។ ប្រជាជនភាគច្រើនដែលបានឆ្លងកាត់របបនេះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ត្រូវបានគេទទួលស្គាល់យ៉ាងទូលាយថាបានទទួលរងនូវជម្ងឺស្លុតបាក់ស្បាត។ អ្នកជំនាញជឿថា “ការចាប់ផ្តើមសកម្មភាពតាមផ្លូវតុលាការនៅចំពោះមុខអ.វ.ត.កក្នុងតុលាការកម្ពុជា អាចបង្កើតជាហានិភ័យថ្មីមួយសម្រាប់សង្គម

[២១] អង្គការលើកលែងទោសអន្តរជាតិ សកម្មភាពជាបន្ទាន់ ៩៣/៩៩ ព្រួយបារម្ភចំពោះសុវត្ថិភាព ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ AI Index ASA ២៣/០៨/៩៩ ទំព័រ ១។

00154279

C5/45

កម្ពុជា"។ បញ្ហានេះអាចនាំឲ្យកើតមានជាថ្មីនូវអារម្មណ៍ខ្វល់ខ្វាយ ហើយបង្កើតផលវិបាកជាអវិជ្ជមានដល់សង្គមតាមក្រោយ[២២]។

៥១. មហាសន្និបាតសហប្រជាជាតិបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ គឺនៅតែជាបញ្ហាកង្វល់មួយដល់សង្គមកម្ពុជា ក៏ដូចជាមនុស្សជាតិដែរ:

> *(...)ដោយគិតទៅដល់ការរំលោភធ្ងន់ធ្ងរលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ នៅតែជាបញ្ហាកង្វល់ដ៏ខ្លាំងរបស់សហគមន៍អន្តរជាតិទាំងមូល*
>
> *ទទួលស្គាល់ថាទំនួលខុសត្រូវរបស់ឧក្រិដ្ឋជនម្នាក់ៗ ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរចំពោះសិទ្ធិមនុស្សគឺជាធាតុផ្សំមួយដ៏សំខាន់នៃការសងសំណងណាមួយ ប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ(...)*[២៣]

៥២. សវនាការជាសាធារណៈលើកទី១របស់អ.វ.ត.ក បានរៀបចំឡើងកាលពីថ្ងៃទី២០ និង២១ ខែវិច្ឆិកា ឆ្នាំ២០០៧នេះ បានបណ្តាលឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋកម្ពុជា និងសារព័ត៌មាន ក៏ដូចជាសហគមន៍អន្តរជាតិ។ អ្នកចូលរួមរាប់រយនាក់ ដូចជាប្រជាពលរដ្ឋ អ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ បានមកចូលរួមស្តាប់សវនាការនេះ។ ចំណាប់អារម្មណ៍នេះបង្ហាញឲ្យឃើញថា ការវិនិច្ឆ័យទោសអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ គឺនៅ

---

[២២] រ៉ប សាវេជ (Rob SAVAGE), "ជម្ងឺស្លុតបាក់ស្មារតី: មរតកនៃការឈឺចាប់ និងអំពើហឹង្សា" សោធអ៊ីស្ទើនគ្លូប (South-Eastern Globe) ខែកក្កដា ឆ្នាំ២០០៧ ទំព័រ២៤-២៧។

[២៣] បុព្វបទ សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត ការជំនុំជម្រះលើខ្មែរក្រហម សេចក្តីសម្រេច លេខ A/RES/57/228 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

តែជាបញ្ហាកង្វល់មួយយ៉ាងខ្លាំង ក្នុងពេលបច្ចុប្បន្ននេះសម្រាប់ប្រជាពលរដ្ឋកម្ពុជា និង សហគមន៍អន្តរជាតិ។

៥៣. អស់រយៈពេលជាង៣០ឆ្នាំមកហើយដែលប្រជាជនកម្ពុជាបានទន្ទឹងរង់ចាំនូវយុត្តិធម៌ ចាំមើលការបញ្ចប់បញ្ហានិទណ្ឌភាព និងភស្តុតាងថាមានអ្វីបានកើតឡើងក្នុងកំឡុងពេលនៃសោកនាដកម្មនេះក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជនខ្មែរ។

៥៤. តាំងពីឆ្នាំ១៩៩៩មក ជនត្រូវចោទត្រូវបានស្គាល់ជាសាធារណៈថាគាត់ធ្លាប់ជាប្រធានមន្ទីរសន្តិសុខ ស-២១ ដែលក្មេង ចាស់ប្រុសស្រីរាប់ពាន់នាក់បានត្រូវឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់។ គាត់ត្រូវបានឃុំខ្លួនតាំងពីពេលនោះមក។ យើងសង្ឃឹមថា គាត់នឹងត្រូវបាននាំយកទៅជំនុំជម្រះទោសនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរបស់អ.វ.ត.កនៅក្នុង ខែមិថុនា ឆ្នាំ២០០៨ ខាងមុខ។ ដូចនេះសណ្តាប់ធ្នាប់សាធារណៈនឹងត្រូវបានរំខាន ប្រសិនបើគាត់ត្រូវបានដោះលែងនៅពេលនេះ។

៥៥. មេធាវីបានអះអាងថា នៅពេលជនត្រូវចោទរស់នៅដោយមានសេរីភាពពីឆ្នាំ១៩៧៩ដល់១៩៩៩ សណ្តាប់ធ្នាប់សាធារណៈមិនត្រូវបានរំខាន។ អង្គបុរេជំនុំជម្រះយល់ឃើញថាស្ថានភាពគឺខុសគ្នាស្រឡះពីស្ថានភាពបច្ចុប្បន្ន ឥឡូវនេះគឺថាអត្តសញ្ញាណជនត្រូវចោទត្រូវបានគេដឹងយ៉ាងច្បាស់ ហើយគាត់បានព្រមទទួលជាសាធារណៈថាគាត់ធ្លាប់ជាប្រធានមន្ទីរសន្តិសុខ ស-២១ ហើយដំណើរការស្វែងរកយុត្តិធម៌បានចាប់ផ្តើមដំណើរការហើយ។ ពីព្រោះតែកាលៈទេសៈខុសគ្នា នោះគ្មានហេតុផលដែលត្រូវជឿជាក់ទៅលើអតីតកាល ដើម្បីយកមកបញ្ជាក់ថា សណ្តាប់ធ្នាប់សាធារណៈនឹងមិនត្រូវបានរំខាន ប្រសិនបើជនត្រូវចោទត្រូវបានដោះលែង។

៥៦. ដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទគឺជាវិធានការមួយដ៏សំខាន់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. ទំព័រ ២២

៥៧. ដោយផ្អែកលើមូលហេតុខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថាសហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នបាន ហើយមូលដ្ឋាននៃដីកានេះនៅតែមានលក្ខណៈគ្រប់គ្រាន់អាចទទួលយកបាន។

៥៨. ជនត្រូវចោទ ស្នើសុំអង្គបុរេជំនុំជម្រះឲ្យដាក់រូបគាត់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីជាសំណងចំពោះការរំលោភពីលើកមុនលើសិទ្ធិរបស់គាត់ដែលត្រូវទទួលបានការជំនុំជម្រះទោសក្នុងរយៈពេលមួយសមស្រប។ គាត់បានស្នើថារូបគាត់អាចដាក់ឲ្យឃុំខ្លួននៅក្នុងផ្ទះបាន។ ក្នុងពេលសវនាការ មេធាវីរបស់គាត់ក៏បានស្នើដែរថា ជនត្រូវចោទអាចត្រូវបានដោះលែង ក្នុងលក្ខខណ្ឌដូចតទៅនេះ៖ (១) ជនត្រូវចោទផ្តល់អសយដ្ឋានរបស់គាត់ដល់អង្គបុរេជំនុំជម្រះ និង (២)ជនត្រូវចោទត្រូវរាយការណ៍រាល់សប្តាហ៍ដល់ប៉ុស្តនគរបាលដែលនៅជិតបំផុត។ មេធាវីទាំងពីរក៏បានបន្ថែមទៀតថាជនត្រូវចោទ គ្មានប្រាក់ គ្មានលិខិតឆ្លងដែន ដូចនេះគាត់មិនអាចចេញក្រៅប្រទេសបានទេ។

៥៩. អង្គបុរេជំនុំជម្រះបានយល់ឃើញថា ក្នុងរឿងក្តីនេះ ឆ្លើយតបទៅនឹងលក្ខខណ្ឌទាំង៥ ដែលមានចែងក្នុងវិធាន ៦៣(៣)នៃវិធានផ្ទៃក្នុង។ ទោះបីមានតែលក្ខខណ្ឌ១ក្នុងចំណោមលក្ខខណ្ឌទាំង៥នេះ គឺអាចយកមកធ្វើជាអំណះអំណាងគ្រប់គ្រាន់ក្នុងការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបាន។ នេះមានន័យថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បីធានាអំពីសន្តិសុខដល់សាក្សី និងជនត្រូវចោទ រក្សាភស្តុតាង ធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះពិចារណាថា ជនត្រូវចោទមិនអាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ ដោយហេតុថាភាពចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន មានទម្ងន់ធ្ងន់ជាងលក្ខខណ្ឌទាំងឡាយដែលស្នើឡើងដោយជនត្រូវចោទ។

៦០. ដូច្នេះ យើងឃើញថាមានហេតុផលគ្រប់គ្រាន់ក្នុងការនិយាយថា ទោះបីជាជនត្រូវចោទត្រូវបានដាក់ឃុំខ្លួននៅក្នុងផ្ទះក៏ដោយ ក៏នៅតែមានហានិភ័យខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់។ ដូចបានបញ្ជាក់ពីមុនមកហើយថា ជនត្រូវចោទនឹងត្រូវមកកាន់អ.វ.ត.ក ក្នុងពេលផ្សេងៗគ្នានៅ ពេលខាងមុខ ហើយមានការពិបាកណាស់ក្នុងការធានាអំពីសុវត្ថិភាពរបស់គាត់ ក្នុងពេលធ្វើដំណើរពីផ្ទះរបស់គាត់មកកាន់អ.វ.ត.ក។ ហេតុផលនេះ គឺគ្រប់គ្រាន់សម្រាប់អង្គបុរេជំនុំជម្រះក្នុងការ បដិសេធសំណើសុំរបស់ជនត្រូវចោទឲ្យដាក់រូបគាត់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

00154282

C5/45

៦១. លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះមិនជឿទុកចិត្តលើលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលអង្គបុរេជំនុំជម្រះអាចដាក់ចេញនោះ អាចធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងពេលសវនាការ និងការការពារអ្នកដទៃទៀត ដូចមានចែងក្នុងវិធាន៦៥(១) នៃវិធានផ្ទៃក្នុង។

## ជំពូក ៧ - ការទាមទារសំណង

៦២. ក្នុងសារណាប្ដឹងឧទ្ធរណ៍របស់សហមេធាវីរបស់ជនត្រូវចោទ បានលើកឡើង ក្នុងការអនុវត្តពាក្យសុំនេះធ្វើឡើងដោយផ្អែកលើលទ្ធផលដែលយល់ឃើញថាជនត្រូវចោទគួរត្រូវបានដោះលែងពីព្រោះតែគាត់ត្រូវបានឃុំខ្លួនខុសច្បាប់ ឬការឃុំខ្លួនគាត់លើសរយៈពេលកំណត់តាមផ្លូវច្បាប់ ដូចខាងក្រោមថាៈ

-ក្នុងករណីសម្រេចឱ្យរួចខ្លួន ត្រូវមានសំណងហិរញ្ញវត្ថុដល់ជនត្រូវចោទ ដែលចាត់ទុកជាសំណងសម្រាប់ការឃុំខ្លួនគាត់រយៈពេល៨ឆ្នាំ រួមជាមួយនឹងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន និងសម្រាប់ព្យសនកម្មដែលគាត់បានទទួលរងពីការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ឬដោះលែង។

-ក្នុងករណីសម្រេចផ្ដន្ទាទោស រយៈពេល៨ឆ្នាំដែលឃុំខ្លួនគាត់នឹងត្រូវបានគិតបញ្ចូលលើរយៈពេលនៃទោសដែលគាត់ត្រូវទទួល ហើយត្រូវផ្ដល់ការកាត់បន្ថយទោសដទៃទៀតដល់គាត់ ដើម្បីជាសំណងសម្រាប់ព្យសនកម្មដែលគាត់បានទទួលរងពីការរំលោភសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ឬដោះលែង[២៤]។

៦៣. ដោយពិចារណាលើលទ្ធផលនៃការរកឃើញរបស់អង្គបុរេជំនុំជម្រះ វាមិនមែនជាការសមស្របសម្រាប់អង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចលើចំនុចទាំងពីរខាងលើនេះ។ អង្គបុរេជំនុំជម្រះ មិនមានហេតុផលសមស្របក្នុងការធ្វើសេចក្ដីសម្រេចចំពោះហេតុការណ៍នីមួយៗនៅពេលដែលស្ថាប័នតុលាការមួយផ្សេងទៀត អាចចាប់យករឿងក្ដីនេះទៅជំនុំជម្រះ និងចេញសេចក្ដីសម្រេចដោយផ្ទាល់ខ្លួនដោយផ្អែកលើភស្តុតាង និងការដាក់សេចក្ដីសន្និដ្ឋានផ្សេងៗ៕

[២៤] សារណាបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១២៧។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C.

**ហេតុដូច្នេះ វិនិច្ឆ័យសេចក្តីជាឯកច្ឆន្ទចំពោះមុខជនត្រូវចោទ:**

១) បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទំរង់

២) សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ

៣) មូលដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន នៅតែមានលក្ខណៈគ្រប់គ្រាន់

៤) បដិសេធចោលពាក្យសុំឲ្យនៅក្រៅឃុំ

៥) ដំកល់ដីកាឃុំរបស់សហចៅក្រមស៊ើបអង្កេត ហើយមូលហេតុដែលបញ្ជាក់ក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយមូលហេតុដែលមានបញ្ជាក់ក្នុងសាលដីកានេះ

៦) បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស(អបជ០១) ទៅឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចាត់ការបន្តតាមច្បាប់

៧) បដិសេធបណ្តឹងឧទ្ធរណ៍ ដោយខុសនឹងគតិច្បាប់

៨) សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង

**សាលដីកានេះប្រកាសជាសាធារណៈ**

ភ្នំពេញ ថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ២០០៧

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING ម៉ែន ពេជ្ជសារី Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន

**ក្រឡាបញ្ជីសវនាការ**

ជួន សុភាសី Anne-Marie Burns